**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ៨២/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## ការធ្វើបទបង្ហាញជូនអង្គទូត ស្តីពីការសម្រេចចិត្តរបស់កម្ពុជា ពាក់ព័ន្ធនឹងតំបន់ទាមទារដែនសមុទ្រត្រួតគ្នាជាមួយ ប្រទេសថៃ

នៅរសៀលថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានអញ្ជើញធ្វើបទបង្ហាញជូនប្រធាន និងតំណាងបេសកកម្មការទូត និងអង្គការអន្តរជាតិនានានៅរាជធានីភ្នំពេញ ស្តីពីការវិវត្តចុងក្រោយបង្អស់ទាក់ទងនឹងស្ថានភាពព្រំដែនកម្ពុជា-ថៃ ដោយផ្តោតសំខាន់លើការចាប់ផ្តើមដំណើរការយន្តការផ្សះផ្សាដោយបង្ខំក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) របស់កម្ពុជា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានចាប់ផ្តើមកិច្ចប្រជុំដោយសម្តែងការអរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសសមាជិកអាស៊ានទាំងអស់ ប្រទេសដៃគូសន្ទនាអាស៊ាន និងមិត្តរបស់កម្ពុជា និងថៃ ដែលបានបន្តគាំទ្រចំពោះបទឈប់បាញ់ និងការខិតខំប្រឹងប្រែងដើម្បីស្វែងរកដំណោះស្រាយដោយសន្តិវិធីនៃជម្លោះព្រំដែនកម្ពុជា-ថៃ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបជូនអ្នកចូលរួមថា នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៦ នេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្ញើសេចក្តីជូនដំណឹងផ្លូវការទៅកាន់ប្រទេសថៃ និងអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីការចាប់ផ្តើមរបស់កម្ពុជាក្នុងការប្រើប្រាស់យន្តការផ្សះផ្សាដោយបង្ខំ ក្រោម UNCLOS ដើម្បីដោះស្រាយដោយសន្តិវិធីលើការទាមទារដែនសមុទ្រត្រួតស៊ីគ្នា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានរំលឹកពីការសោកស្តាយ និងការខកចិត្តយ៉ាងជ្រាលជ្រៅរបស់កម្ពុជាចំពោះការសម្រេចចិត្តរបស់ប្រទេសថៃ ក្នុងការដកខ្លួនជាឯកតោភាគីចេញពីអនុស្សរណៈនៃការយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ទាក់ទងនឹងតំបន់ទាមទារដែនសមុទ្រត្រួតគ្នានៃខ្ពង់រាបបាតសមុទ្រ (MOU-2001)។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា MOU-2001 បានឆ្លុះបញ្ចាំងពីឆន្ទៈ និងចេតនាពិតប្រាកដរបស់ប្រទេសទាំងពីរ ក្នុងការធ្វើការរួមគ្នាដោយស្មោះត្រង់ និងអនុលោមតាមច្បាប់អន្តរជាតិ ដើម្បីដោះស្រាយព្រំដែនសមុទ្រដោយសន្តិវិធី និងអភិវឌ្ឍធនធានរួមគ្នានៅក្នុងតំបន់ទាមទារដែនសមុទ្រត្រួតគ្នា។ រយៈពេល២៥ឆ្នាំកន្លងមកនេះ MOU-2001 គឺជាក្របខណ្ឌទ្វេភាគីតែមួយគត់ ដែលភាគីទាំងពីរពឹងផ្អែកលើ ដើម្បីដោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នារបស់ខ្លួន។ ដោយសារថៃបានដកខ្លួនចេញពី MOU-2001 បន្ទាប់ពីបានពិចារណាដោយប្រុងប្រយ័ត្ននូវរាល់ជម្រើសប្រកបដោយសន្តិភាព និងស្របច្បាប់ កម្ពុជាយល់ថា គ្មានជម្រើសផ្សេងក្រៅពីផ្តើមដំណើរការផ្សះផ្សាដោយបង្ខំ ក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) នោះទេ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានរំលឹកផងដែរអំពីដំណើរការផ្សះផ្សាដោយបង្ខំលើកដំបូងក្រោម UNCLOS រវាងប្រទេសទីម័រឡេស្តេ និងអូស្ត្រាលី ដែលត្រូវបានបញ្ចប់ដោយជោគជ័យជាមួយនឹងការដោះស្រាយព្រំដែនសមុទ្រដោយសន្តិវិធីក្នុងឆ្នាំ២០១៨។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានសម្តែងក្តីសង្ឃឹមថា តាមរយៈការផ្តើមយន្តការផ្លូវច្បាប់ដោយសន្តិវិធីក្រោម UNCLOS នេះ កម្ពុជាអាចបង្ហាញពីតម្លៃនៃច្បាប់អន្តរជាតិ និងដំណោះស្រាយជម្លោះដោយសន្តិវិធី ក្នុងការការពារអធិបតេយ្យ ការពង្រឹងទំនុកចិត្ត ការបើកលទ្ធភាពប្រើប្រាស់ធនធាន ការគាំទ្រការអភិវឌ្ឍ និងការរួមចំណែកដល់សន្តិភាព និងស្ថិរភាព មិនត្រឹមតែសម្រាប់កម្ពុជា និងថៃប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់តំបន់ទាំងមូលផងដែរ នេះជាលើកទី២ក្នុងប្រវត្តិសាស្ត្រនៃអនុសញ្ញានេះផងដែរ។

ជាចុងក្រោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការដោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នាជាមួយប្រទេសថៃដោយសន្តិវិធី និងបានសម្តែងក្តីសង្ឃឹមយ៉ាងមុតមាំថា ប្រទេសទាំងពីរនឹងអាចសម្រេចបាននូវដំណោះស្រាយមួយដោយយុត្តិធម៌ និងយូរអង្វែង៕

ថ្ងៃអង្គារ ២រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៦